**សេចក្តីប្រកាសកែប្រែរបៀបដាក់ពាក្យផ្តាំផ្ញើពីសាធារណជនទៅកាន់កិច្ចប្រជុំ គណៈកម្មការសាលារៀន - ថ្ងៃទី18 ខែវិច្ឆិកា 2020:**

ដើម្បីការពារជម្ងឺ កូវិដ-១៩ មិនអោយរាលដាលច្រើន គឺកិច្ចប្រជុំគណៈកម្មការសាលារៀន នៅថ្ងៃទី18 ខែវិច្ឆិកា នឹងបង្កើតឡើងទាំងស្រុង តាមរយៈធ្វើពីចម្ងាយ ដោយគ្មានមនុស្សចូលរួមផ្ទាល់ ទាំងសមាជិកគណៈកម្មការសាលារៀន ទាំងបុគ្គលិក ទាំងសាធារណជន ។ សមាជិកគណៈកម្មការសាលារៀន និង បុគ្គលិកនឹងជួបជុំគ្នាតាមរយៈ Zoom ដែលនឹងចាក់បង្ហាញអោយឃើញភ្លាមៗនៅតាម www.lbschools.net/youtube ។ ពាក្យផ្តាំផ្ញើពីសាធារណជនសម្រាប់រាប់បញ្ចូល គឺនឹងប្រើតាមប្រព័ន្ធ ទូរស័ព្ទ ដូចតាមការរៀបរាប់នៅផ្នែកខាងក្រោម ។ សាធារណជនក៏អាចដាក់ពាក្យផ្តាំផ្ញើផ្ទាល់បានដែរតាម អ៊ីម៉ែល ទៅកាន់សមាជិកគណៈកម្មការសាលារៀន ដោយប្រើបណ្តាញ https://www.lbschools.net/Board_of_Education/ ។ ពាក្យផ្តាំផ្ញើតាម ទូរស័ព្ទ នឹងចាក់បង្ហាញស្តាប់ក្នុងពេលប្រជុំ ។

គណៈកម្មការនាយកផ្នែកសិក្សាធិការ ផ្តល់តម្លៃមកលើពាក្យផ្តាំផ្ញើ និង ជម្រុញអោយសាធារណជនបង្ហាញដាក់ពាក្យផ្តាំផ្ញើក្នុងកិច្ចប្រជុំ ។

**សេចក្តីថ្លែងការណ៍តាម ទូរស័ព្ទ**

ពាក្យផ្តាំផ្ញើជាសម្លេងក្នុង ទូរស័ព្ទ គឺជាកម្មសិទ្ធិសាធារណៈ នៅពេលណាបានថតបញ្ចូលភ្លាម ។ សាធារណជនម្នាក់ណាក៏ដោយ គឺអាចស្នើសុំដាក់ពាក្យផ្តាំផ្ញើថតជាសម្លេងបាន ។ មានចំនួន បី នាទីសម្រាប់បើកទទួលការដាក់ពាក្យផ្តាំផ្ញើ ។ សាធារណជនអាចដាក់ពាក្យផ្តាំផ្ញើបានតែមួយលើកប៉ុណ្ណោះមកលើកិច្ចការលើកបង្ហាញក្នុងរបៀបវារៈ និង ពាក្យផ្តាំផ្ញើមួយលើកទៀតមកលើកិច្ចការ ដែលគ្មានបង្ហាញក្នុងរបៀបវារៈ ដោយប្រើពេលដាច់ដោយឡែកមួយផ្សេង ។ សូមចងចាំថា ពាក្យផ្តាំផ្ញើមកលើកិច្ចការ ដែលគ្មានបង្ហាញក្នុងរបៀបវារៈ គឺមិនអាចឆ្លើយជូនវិញបានទេក្នុងពេលកំពុងប្រជុំ ។ ប៉ុន្តែ សមាជិកគណៈកម្មការសាលារៀននឹងយកចិត្តទុកដាក់ស្តាប់យ៉ាងដិតដល់ទៅកាន់ពាក្យផ្តាំផ្ញើទាំងអស់នោះ ហើយជារឿយៗ គឺពាក្យផ្តាំផ្ញើទាំងអស់នោះឯងនឹងក្លាយទៅជាការលើកពិគ្រោះសម្រាប់ថ្ងៃមុខក្នុងកិច្ចប្រជុំគណៈកម្មការសាលារៀន នៅពេលណាអាចរាប់បញ្ចូលក្នុងរបៀបវារៈបាន ។

បើគ្មានពេលគ្រប់គ្រាន់សម្រាប់ចាក់ស្តាប់ពាក្យផ្តាំផ្ញើមកពីសាធារណជននោះទេ គឺពាក្យផ្តាំផ្ញើនៅសល់នឹងផ្ញើបញ្ជូនទៅកាន់សមាជិកគណៈកម្មការសាលារៀនផ្ទាល់ ។

សូមចងចាំថា មានកូនក្មេងតែងតែបើកស្តាប់កិច្ចប្រជុំ ។ ដូច្នេះ សូមមេត្តាប្រើពាក្យ និង ភាសាអោយសមស្របតាមអាយុកូនក្មេង ។ ដោយមូលហេតុថា យើងទទួលការតម្រូវអោយធ្វើការបង្ហាញថា តើពាក្យផ្តាំផ្ញើសមស្របតាមកិច្ចការដាក់បញ្ចូលក្នុងរបៀបវារៈ ឬ ក៏អត់ ហើយបើសមស្រប តើកិច្ចការមួយណាក្នុងរបៀបវារៈ ដែលត្រូវបានដោះស្រាយ គឺមានតែពាក្យផ្តាំផ្ញើ ដែលបានទទួល បន្ទាប់ពីមានការតាំងបង្ហាញរបៀបវារៈផុតទៅហើយប៉ុណ្ណោះ ទើបអាចយកមកចាក់ស្តាប់បានក្នុងពេលប្រជុំ ។ ចំពោះសាធារណជន ដែលចង់ដាក់ពាក្យផ្តាំផ្ញើក្នុងពេលកំពុងជួបប្រជុំគណៈកម្មការសាលារៀន គឺគួរប្រើតាមមធ្យោបាយដូចតទៅ:

អោយទាន់ពេលថ្ងៃត្រង់នៅចំថ្ងៃប្រជុំ សូមប្រើទូរស័ព្ទទាក់ទងទៅកាន់លេខ 562-242-2190 ដើម្បីថតសម្លេងដាក់ពាក្យផ្តាំផ្ញើ និង ធ្វើតាមអ្វីបង្ហាញអោយធ្វើជាបន្តបន្ទាប់ទៅ ។ ពាក្យផ្តាំផ្ញើទាំងអស់គួរផ្តើមធ្វើឡើងដោយរាយបង្ហាញជាពត៌មានដូចតទៅ:

- ឈ្មោះរបស់អ្នក និង កិច្ចការក្នុងរបៀបវារៈ ដែលអ្នកចង់បានអោយមានការដោះស្រាយជាមួយ ។
- កិច្ចប្រជុំមួយណា ដែលអ្នកចង់បានអោយពាក្យផ្តាំផ្ញើរបស់អ្នកទទួលការអានអំពី ។

បើពាក្យផ្តាំផ្ញើរបស់អ្នកនៅតាមទូរស័ព្ទគ្មានការបង្ហាញអំពីកិច្ចការណាមួយច្បាស់លាស់នោះទេក្នុងរបៀបវារៈសម្រាប់សុំអោយដោះស្រាយជាមួយ គឺវានឹងយកទៅដាក់នៅលើកិច្ចការ ដែលមិនរាប់បញ្ចូលក្នុងរបៀបវារៈសម្រាប់ការពិគ្រោះជាសាធារណៈ ។

បើអ្នកមានបញ្ហាផ្សេងៗ ដែលធ្វើអោយអ្នកមិនអាចដាក់ពាក្យផ្តាំផ្ញើរបស់អ្នកបានតាមវិធីណាមួយក៏ដោយដូចបានរាយបង្ហាញមក គឺសូមអញ្ជើញធ្វើការទាក់ទងអ្នកស្រី Leticia Rodriguez តាមលេខទូរស័ព្ទ 562-997-8240 ។